**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ការចំណាយដោយឡែក សំរាប់អនុវត្តកម្មវិធី សកម្មភាពជាអាទិភាព នៅក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ-បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការកំណត់ប្រាក់បេសកកម្មក្នុងប្រទេស
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០២

## សំរេច

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការចំណាយដោយឡែក សំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (PAP) ដែលប្រើប្រាស់ ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាតែប៉ុណ្ណោះ ។

**មាត្រា ២.-**

ការចំណាយដោយឡែកទាំងអស់នេះ ត្រូវអនុវត្តសំរាប់កម្មវិធីសកម្មភាពជាអាទិភាព( PAP ) ចាប់ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ តទៅ ។

**មាត្រា ៣.-**

ប្រាក់ឧបត្ថម្ភសំរាប់គ្រូបង្រៀនដែលត្រូវទទួលបានក្នុងកម្មវិធីសកម្មភាពជាអាទិភាព (PAP) ត្រូវកំណត់ដូចខាងក្រោម :

| កម្មវិធី | គ្រូដែលត្រូវទទួលប្រាក់ឧបត្ថម្ភ | ប្រាក់ឧបត្ថម្ភ |
|---|---|---|
| ១.ប្រសិទ្ធភាពនៃសេវាអប់រំ | **កម្មវិធីគាំទ្រការងារគ្រប់គ្រង និងបច្ចេកទេស**<br>( តាមការប្រលងប្រណាំង ) | ( ឧបត្ថម្ភក្នុងរយៈពេល ៤ឆ្នាំ ) |
| | -ប្រធានមន្ទីរអប់រំ យុវជននិងកីឡា ខេត្ត ក្រុង | ឧបត្ថម្ភ ក្នុង១ឆ្នាំ ៦០០.០០០រៀលក្នុង១នាក់ |
| | -ប្រធានការិយាល័យអប់រំ យុវជននិងកីឡា ស្រុក ខណ្ឌ | ឧបត្ថម្ភ ក្នុង១ឆ្នាំ ៥០០.០០០រៀលក្នុង១នាក់ |
| | -នាយក សាលារៀន | ឧបត្ថម្ភ ក្នុង១ឆ្នាំ ៣០០.០០០រៀលក្នុង១នាក់ ។ |
| | **កម្មវិធីផ្លាស់គ្រូ** | |
| | -គ្រូដែលត្រូវផ្លាស់ ក្នុងឃុំ | ឧបត្ថម្ភ ម្តងគត់ ៣០០.០០០រៀលក្នុង១នាក់ |
| | -គ្រូដែលត្រូវផ្លាស់ ឆ្លងឃុំ | ឧបត្ថម្ភ ម្តងគត់ ៥០០.០០០រៀលក្នុង១នាក់ |
| | -គ្រូដែលត្រូវផ្លាស់ ឆ្លងស្រុក | ឧបត្ថម្ភ ម្តងគត់ ៨០០.០០០រៀលក្នុង១នាក់ |
| | -គ្រូដែលត្រូវផ្លាស់ ឆ្លងខេត្តវាលរាប | ឧបត្ថម្ភ ម្តងគត់ ១.០០០.០០០រៀលក្នុង១នាក់ |
| | -គ្រូដែលត្រូវផ្លាស់ឆ្លងខេត្តដាច់ស្រយាល | ឧបត្ថម្ភ ម្តងគត់ ១.៥០០.០០០រៀលក្នុង១នាក់ ។ |
| | **លើកកំពស់ជីវភាពគ្រូនៅតាមតំបន់ដាច់ស្រយាល និង តំបន់ជួបការលំបាក**<br>( អនុវត្តចាប់ពីខែតុលាឆ្នាំ ២០០២ ) | |
| | - គ្រូតំបន់ជួបការលំបាក | ឧបត្ថម្ភ ប្រចាំខែ ៤០.០០០រៀលក្នុង១នាក់ |
| | - គ្រូតំបន់ដាច់ស្រយាល ( ទីរួមខេត្ត ) | ឧបត្ថម្ភ ប្រចាំខែ ៥០.០០០រៀលក្នុង១នាក់ |
| | - គ្រូតំបន់ដាច់ស្រយាល ( ជនបទ) | ឧបត្ថម្ភ ប្រចាំខែ ៦០.០០០រៀលក្នុង១នាក់ ។ |

| | | |
|---|---|---|
| ២_គុណភាព និងប្រសិទ្ធភាពនៃការអប់រំ បឋមសិក្សា | **គ្រូដែលបង្រៀនល្អ**<br>- គ្រូបង្រៀនល្អ ចំណាត់លេខ ១<br>-គ្រូបង្រៀនល្អ ចំណាត់លេខ ២<br>- គ្រូបង្រៀនល្អ ចំណាត់លេខ ៣ | ឧបត្ថម្ភក្នុងមួយឆ្នាំ សិក្សា១២០.០០០រៀលក្នុង១នាក់<br>ឧបត្ថម្ភក្នុងមួយឆ្នាំ សិក្សា១០០.០០០រៀលក្នុង១នាក់<br>ឧបត្ថម្ភក្នុងមួយឆ្នាំសិក្សា ៨០.០០០រៀលក្នុង១នាក់ ។ |
| | **បំប៉នសិស្សខ្សោយ**<br>អ្នកគ្រប់គ្រងក្នុងពេលបំប៉ន<br>យ៉ាងច្រើន ២នាក់ ក្នុង១កំរងសាលារៀន | ឧបត្ថម្ភជូន ប្រចាំខែដោយយកមូលដ្ឋាន តារាងបើកបៀវត្ស ខែមិថុនា នៃឆ្នាំដែលបង្រៀន ដោយឡែក ឆ្នាំ២០០២ ត្រូវយកតារាងបើកបៀវត្ស ខែធ្នូ ឆ្នាំ២០០១ ។ |
| ៣_គុណភាព និង ប្រសិទ្ធភាព នៃការអប់រំ បណ្តុះបណ្តាល បច្ចេកទេស | អ្នកឯកទេសដែលជួលពីខាងក្រៅក្របខ័ណ្ឌ រដ្ឋមកបង្រៀនវិជ្ជាជីវៈ | ឧបត្ថម្ភប្រចាំខែយ៉ាងច្រើន ៤៥០.០០០រៀលក្នុង១នាក់ ដោយអនុវត្តការជ្រើសរើសតាមនីតិវិធីលទ្ធកម្ម សាធារណៈ ។ |
| | គ្រូឧទ្ទេសដែលជួលពីខាងក្រៅក្របខ័ណ្ឌរដ្ឋមក បំប៉នគ្រូអប់រំ បច្ចេកទេស និង វិជ្ជាជីវៈ | ឧបត្ថម្ភជារបបម៉ោង យ៉ាងតិច ២០.០០០រៀល និង យ៉ាងច្រើន ៤០.០០០រៀល/១ម៉ោង ។ |
| ៤_ការពង្រីក អប់រំក្រៅ ប្រព័ន្ធ | អ្នកឯកទេសដែលជួលពីខាងក្រៅក្របខ័ណ្ឌ រដ្ឋមកបង្រៀនវិជ្ជាជីវៈ នៅ មជ្ឈមណ្ឌល សិក្សាសហគមន៍ | ឧបត្ថម្ភប្រចាំខែយ៉ាងច្រើន ៣៦០.០០០រៀលក្នុង១នាក់ ដោយអនុវត្តការជ្រើសរើសតាមនីតិវិធីលទ្ធកម្ម សាធារណៈ ។ |

**មាត្រា ៤.-**

របបបេសកកម្មជាទូទៅ ត្រូវបានអនុវត្តដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ នៃ អនុក្រឹត្យលេខ ០៧ អនក្រ-បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ។ ដោយសារកម្មវិធីសកម្មភាព ជាអាទិភាព(PAP) ត្រូវ ប្រតិបត្តិផ្ទាល់ជាមួយស្រុក ខណ្ឌ ទូទាំងប្រទេស ចំពោះប្រាក់បេសកកម្ម នៅក្នុងខេត្ត ក្រុង ត្រូវកំណត់ដូចខាងក្រោម ៖

-បេសកកម្មមិនឆ្លងស្រុក ខណ្ឌ

• ឧបត្ថម្ភបេសកកម្ម ៨.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ

• សោហ៊ុយចំណាយផ្សេងៗ ( ធ្វើដំណើរ-ហូបចុក-ស្នាក់នៅ ) : គ្មាន

-បេសកកម្មឆ្លងស្រុក ខណ្ឌ ( ចំងាយផ្លូវលើសពី ២០គីឡូម៉ែត្រ )

• ឧបត្ថម្ភបេសកកម្ម ៨.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ

• ឧបត្ថម្ភប្រាក់ហូបចុក ១៥.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ ។

## មាត្រា ៥..

និស្សិតចុះធ្វើសកម្មភាពប្រតិបត្តិ និង ធ្វើការងារស្រាវជ្រាវឆ្លងខេត្ត ក្រុង ក្នុងកម្មវិធីគុណភាព និង ប្រសិទ្ធភាពនៃការអប់រំ នៅឧត្តមសិក្សា ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៥.០០០រៀល ក្នុង១ថ្ងៃ ក្នុងនិស្សិត១នាក់ សំរាប់រយៈពេលយ៉ាងច្រើន ១០ថ្ងៃក្នុង១ឆ្នាំសិក្សា ។

## មាត្រា ៦..

ចំពោះការរៀបចំវគ្គបំប៉ន សំរាប់កម្មវិធីសកម្មភាពជាអាទិភាព(PAP)ទាំងអស់ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

ក-ប្រាក់ឧបត្ថម្ភអ្នកចូលរួម :

| | |
|---|---|
| -គ្រូឧទ្ទេស | ២០.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ |
| -អ្នកបកប្រែ | ២០.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ |
| -អ្នកសំរបសំរួល | ១៥.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ |
| -សមាជិកចូលរួម ( ក្នុងករណីដែលវគ្គបំប៉ន-មិនលើសពី១០ថ្ងៃ ) | ១០.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ |

ខ-សោហ៊ុយផ្សេងៗ :ចំណាយសំរាប់ការស្រាវជ្រាវឯកសារ សំភារៈ អាហារសំរន់ និង ចំណាយផ្សេងៗ ក្នុងការរៀបចំ គ្រប់គ្រងដំណើរការវគ្គបំប៉ន ត្រូវយកចំនួនសរុបអ្នកចូលរួមធ្វើជាមូលដ្ឋានគិត ដើម្បីផ្តល់ជូនយ៉ាងច្រើន ចំនួន ២០.០០០រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ ។

## មាត្រា ៧..

ចំពោះការប្រជុំ ដែលមានកម្មវិធីច្បាស់លាស់ ដើម្បីរៀបចំអនុវត្ត កម្មវិធីសកម្មភាពជាអាទិភាព (PAP) នីមួយៗចំណាយក្នុងការរៀបចំឯកសារ និង គ្រប់គ្រងដំណើរការប្រជុំ ត្រូវយកចំនួនសរុបអ្នកចូលរួមប្រជុំធ្វើជាមូលដ្ឋានគិត ដើម្បីផ្តល់ជូនយ៉ាងច្រើនចំនួន ៥.០០០រៀលក្នុង១នាក់ ក្នុង១ពេល ដោយគិត១ថ្ងៃ ២ ពេល ។

**មាត្រា ៨.-**

សាលារៀនដែលអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ( PAP ) អំពី គុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សាទទួលបានលទ្ធផលល្អ ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

-សាលារៀន ចំណាត់ថ្នាក់ លេខ១ ២៥០.០០០រៀល ក្នុង១សាលា ក្នុង១ឆ្នាំ

-សាលារៀន ចំណាត់ថ្នាក់ លេខ២ ២០០.០០០រៀល ក្នុង១សាលា ក្នុង១ឆ្នាំ

-សាលារៀន ចំណាត់ថ្នាក់ លេខ៣ ១៨០.០០០រៀល ក្នុង១សាលា ក្នុង១ឆ្នាំ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១០

- កាលប្បវត្តិ-ឯកសារ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] , ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន